# របាយការណ៍
# ស្តីពី
# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែកក្កដា ឆ្នាំ២០១០
# និង ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែសីហា ឆ្នាំ២០១០

(០១/០៧/២០១០-៣០/០៧/២០១០)

អនុវត្តតាមផែនការសកម្មភាពឆ្នាំ២០១០ស្តីពីការត្រួតពិនិត្យគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តដឹកនាំក្រសួងជាសមាជិក, គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងបំផុសលើកទឹកចិត្តឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និង វិស័យឯកជន អនុវត្តវិធានការពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀន

### ១. សភាពការណ៍គ្រឿងញៀនអន្តរជាតិ

តាមព័ត៌មានពីមន្ទីរប្រឆាំងគ្រឿងញៀនបានឱ្យដឹងថា ក្នុងឱកាសកីឡាបាល់ទាត់ដណ្តើមពានរង្វាន់ពិភពលោក ពួកឈ្មួញគ្រឿងញៀនអន្តរជាតិ បានបន្លំសូនជារូបពានរង្វាន់ដែលមានទម្ងន់១១គីឡូក្រាមធ្វើអំពី កូកាអ៊ីន និង សារធាតុគីមីអាសេតោន ហើយបញ្ជូនតាមប៉ុស្តិ៍ប្រៃសណីយ៍នៅព្រលានយន្តហោះកូបូតានៃប្រទេសកូឡំប៊ី ក្នុងទិសដៅ ឆ្ពោះទៅកាន់ប្រទេសអេស្បាញ ប៉ុន្តែករណីនេះត្រូវបាននគរបាលប្រឆាំងគ្រឿងញៀនប្រទេសកូឡំប៊ីរកឃើញនិងចាប់បានកាលពីថ្ងៃទី០៤ ខែ កក្កដា ឆ្នាំ ២០១០ ។

### ២. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

ខែកក្កដានេះ ក៏ដូចបណ្តាខែមុនៗ មេតំហ្វេតាមីនគ្រាប់ និង មេតំហ្វេតាមីនទឹកកក នៅតែជាប្រភេទគ្រឿងញៀននាំមុខគេ ដែលពួកឈ្មួញគ្រឿងញៀនក្នុងតំបន់បានប្រើប្រាស់ក្រុមឈ្មួញនៃប្រទេសជិតខាងកម្ពុជា ឱ្យនាំចូលមកកម្ពុជាតាមច្រករបៀងមួយចំនួននៃបណ្តាខេត្តភាគឥសានប្រទេស ។ គ្រឿងញៀនទាំងនោះ ត្រូវបានពួកឈ្មួញនាំចេញពីកម្ពុជាឆ្ពោះទៅកាន់តំបន់ព្រំដែនភាគពាយ័ព្យប្រទេសនិងមួយចំនួនទៀតត្រូវបាននាំចេញពីកម្ពុជាឆ្ពោះទៅកាន់ប្រទេសវៀតណាមតាមច្រក

របៀងនៃខេត្តតាយនិញ ។ ការនាំចូលគ្រឿងញៀនតាមច្រកព្រំដែនភាគឥសានប្រទេស ក្នុងខែកក្កដានេះ គឺមានមួយករណីដែលធ្វើសកម្មភាពនាំចូលតាមច្រកព្រំដែននៃខេត្តព្រះវិហារដោយក្រុមឈ្មួញមកពីប្រទេសឡាវ ។ ដោយឡែក ការនាំចេញទៅកាន់ប្រទេសវៀតណាមវិញ ក៏មាន១ករណី(មេតំហ្វេតាមីនទឹកកក)ផងដែរ ដែលធ្វើសកម្មភាពដោយជនជាតិអូស្ត្រាលីមានដើមកំណើតវៀតណាមក្នុងចំនួនមួយគួរកត់សំគាល់ ។ ក្រៅពីនេះ គឺនៅមានការចរាចរចែកចាយទ្រង់ទ្រាយតូចៗជាច្រើនកន្លែងដែលរាជធានី-ខេត្តមួយចំនួនបង្ក្រាបបានជាបន្តបន្ទាប់ ។

## II . លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន :

### *ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*

លើការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឯកឧត្តម នាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រីប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់លើការចង្អុលណែនាំនិងដឹកនាំវិធានការពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាអាទិ៍ :

-ការអញ្ជើញចុះទៅពិនិត្យនិងស្វែងយល់ពីមណ្ឌលបណ្តោះអាសន្ន អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន "ឱកាសខ្ញុំ" (១៤/៧/២០១០) ។

-ការសិក្សាស្វែងយល់ពីកម្មវិធីព្យាបាល កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងការធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀនទៅក្នុងសហគមន៍ របស់អង្គការមិត្តសំឡាញ់ (១៥/៧/២០១០)។

-ការអនុញ្ញាតឱ្យក្រុមប្រតិភូបច្ចេកទេសវៀតណាមចូលជួបសំដែងការគួរសមនិងពិភាក្សាការងារ(២៩/៧/១០)។

-ការកែសម្រួលសមាសភាព របស់ក្រុមការងារអន្តរក្រសួងសមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

-ការកែសម្រួលសមាសភាព ក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ។

-ការជំរុញការរៀបចំផែនការសកម្មភាពជាតិ ៥ ឆ្នាំ លើកទី២(២០១១-២០១៥)ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

### *១.ការកាត់បន្ថយតម្រូវការគ្រឿងញៀន :*

ចំពោះការកាត់បន្ថយតម្រូវការគ្រឿងញៀន អាជ្ញាធរជាតិបានបន្តយកចិត្តទុកដាក់ជំរុញដល់ក្រសួងជាសមាជិក និង បំផុសលើកទឹកចិត្តឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល និង វិស័យឯកជន ដើម្បីធ្វើការផ្សព្វផ្សាយអប់រំសំដៅលើកកំពស់ការយល់ដឹងជាសាធារណៈពីគ្រោះថ្នាក់នៃគ្រឿងញៀន ជាអាទិ៍មាន :

-ការពិភាក្សាជាមួយមន្ត្រីជំនាញរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អំពីការបង្កើតផ្ទាំងរូបភាព-ខិត្តប័ណ្ណ ដែលមានខ្លឹមសាររួមបញ្ចូលគ្នា សំរាប់ធ្វើការផ្សព្វផ្សាយនៅតាម សណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត នានា (០៨/៧/២០១០) ។

ដោយឡែក ក្រសួងជាសមាជិក អជបគញ រួមមាន :

-ក្រសួងអប់រំយុវជន និង កីឡា បានបង្កើតគណៈកម្មាធិការអន្តរនាយកដ្ឋានប្រយុទ្ធនឹងជម្ងឺអេដស៍ និង គ្រឿងញៀន ។ គណៈកម្មាធិការនេះ បានធ្វើការបញ្ចូលកម្មវិធីអប់រំពីគ្រឿងញៀនទៅក្នុងកម្មវិធីសិក្សា ថ្នាក់ទី៧ និងថ្នាក់ទី៨ តាមមុខវិជ្ជា វិទ្យាសាស្ត្រ ក្នុងមេរៀនគ្រឿងញៀន ព្រមទាំងបានធ្វើការអភិវឌ្ឍឯកសារបង្រៀន និង

ញៀន ។ ក្រៅពីនេះ ក្រសួងបានធ្វើការបណ្តុះបណ្តាល ក្រុមការងារបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុក, គ្រូថ្នាក់ទី៥ ទី៦ នៅតាមខេត្តគោលដៅចំនួន១៤, ភ្នាក់ងារមិត្តអប់រំមិត្ត និងបានរៀបចំសិក្ខាសាលាជាច្រើនវគ្គ ស្តីពីផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន ។

-ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និង ក្រសួងពាណិជ្ជកម្ម បានធ្វើការណែនាំដល់ក្រុមហ៊ុន រោងចក្រ សិប្បកម្ម ដែលផលិត ផលិតផលមានការវេចខ្ចប់ ជាពិសេស ទឹកពិសាដប ឱ្យធ្វើការបោះពុម្ពសារអប់រំពីគ្រឿងញៀន នៅលើស្លាកផលិតផលរបស់ខ្លួន ។

-ក្រសួងព័ត៌មាន បានបន្តជំរុញឱ្យប្រព័ន្ធផ្សព្វផ្សាយ ដូចជា វិទ្យុ ទូរទស្សន៍រដ្ឋ-ឯកជន សារព័ត៌មាន ធ្វើការផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀនឱ្យកាន់តែសកម្មថែមទៀត ជាពិសេស ការធ្វើកិច្ចសម្ភាសន៍ពីបញ្ហាគ្រឿងញៀន នៅ ក្នុងកម្មវិធីនានា របស់អគ្គនាយកដ្ឋានវិទ្យុ និង ទូរទស្សន៍ជាតិកម្ពុជា ។

ដោយឡែក បណ្តាខេត្តនិងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ក៏បានបន្តការយកចិត្តទុកដាក់ចូលរួមក្នុងការផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀននេះ ជាពិសេស តាមរយៈទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សរុបបានចំនួន **៣៨.៩៧៤** នាក់( រាប់ទាំងខេត្តបន្ទាយមានជ័យដែលបានបញ្ចូលតួលេខទៅក្នុងខែមិថុនារួចហើយ គឺមានចំនួន ៤១.៨៥៥ នាក់) ។

## ***២-ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន :***

### ***២.១-អំពីការបង្ក្រាបបទល្មើសគ្រឿងញៀន***

ខែកក្កដាឆ្នាំ២០១០ បង្ក្រាបបទល្មើសបាន **២៦ ករណី** ឃាត់ខ្លួនជនល្មើស **៥៥** នាក់( ប្រុស៤២នាក់, ស្រី ១៣ នាក់) ក្នុងនោះ ជនជាតិខ្មែរ ៥២នាក់( ប្រុស៤០នាក់ ស្រី១២នាក់), វៀតណាម ១នាក់( ស្រី), ឡាវ ២នាក់( ប្រុស) ។

**វត្ថុតាងចាប់យក** មេតំហ្វេតាមីន **WY ២.៣៤៣** គ្រាប់, ម្សៅមេតំហ្វេតាមីន **ICE ៩៣៤,៥៦** ក្រាម, អ៊ិចស្តាស៊ី ៤០៤ គ្រាប់, ម្សៅពណ៌ផ្កាឈូក ៣៩ ក្រាម, ជញ្ជីង២, កាំភ្លើងខ្លី១ដើម, រថយន្ត៤គ្រឿង, ម៉ូតូ១គ្រឿង, ឧបករណ៍ប្រើប្រាស់ និង វេចខ្ចប់គ្រឿងញៀនមួយចំនួន ។ ជាមួយនេះដែរ :

-រាជធានីភ្នំពេញ បានធ្វើការដុតកំទេចចោលគ្រឿងញៀនចំនួន ២៤.៩១៧ គ្រាប់ និង ៨.១៤៣,៥១២ ក្រាម ។

-ខេត្តបាត់ដំបង បានដុតកំទេចចោលគ្រឿងញៀនចំនួន ២០.៧៧៥ គ្រាប់, ៤៤១ ក្រាម និង ៥២កញ្ចប់តូច ។

-ខេត្តព្រះវិហារ បានដុតកំទេចគ្រឿងញៀនចំនួន ២៣.៤៣៥ គ្រាប់ ។

-ខេត្តកំពង់ចាម បានដុតកំទេចមេតំហ្វេតាមីន ៣៦៦១៣ គ្រាប់ ថ្នាំគ្រាប់ផ្សេងៗចំនួន ទម្ងន់ ២៩៩,៧០ ក្រាម មេតំហ្វេតាមីនទឹកកកក និងម្សៅពណ៌សចំនួន ១៣៨ កញ្ចប់ កញ្ឆាក្រៀម ១៤,៨ គ.ក្រ ។

-ខេត្តពោធិសាត់ បានសហការជាមួយកម្លាំងរបស់រដ្ឋបាលព្រៃឈើ ចុះទៅកំទេចកន្លែងផលិតប្រេងម្រះព្រៅភ្នំចំនួន ២កន្លែង និងចាប់យក ប្រេងម្រះព្រៅភ្នំចំនួន ៣៣ ប៊ីដុង, ឆ្នាំងចំហុយ ២, ម៉ាស៊ីនបូមទឹក ១គ្រឿង ។

### ***២.២-អំពីទិន្នន័យសារធាតុគីមីផ្សំ***

អគ្គលេខាធិការដ្ឋាន បានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ធ្វើការប្រមូលទិន្នន័យសារធាតុគីមីផ្សំ ដែលមាន

អាជ្ញាប័ណ្ណនាំចូលប្រចាំខែកក្កដាឆ្នាំ២០១០ សរុបមានចំនួន **1.990.200 Kgs** ។

### *៣. ការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងការកាត់បន្ថយគ្រោះថ្នាក់នានា :*

**ចំពោះការព្យាបាលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន** អាជ្ញាធរជាតិបានចាត់តាំងមន្ត្រីបច្ចេកទេសចំនួន២រូប ដើម្បីចូលរួមជាសមាជិកក្រុមការងារថ្នាក់ខ្ពស់ នៃកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀន ប្រភេទអាភៀន ដោយប្រើឱសថជំនួស( កម្មវិធីមេតាដូន) របស់ក្រសួងសុខាភិបាល ។

ដោយឡែក អគារពេទ្យមួយខ្នងស្ថិតនៅក្នុងមណ្ឌល ពិភពនៃក្តីសង្ឃឹម ខេត្តបាត់ដំបង ដែលជាជំនួយរបស់អាជ្ញាធរជាតិ ត្រូវបានសាងសង់រួចរាល់ជាស្ថាពរ ក្នុងនោះ មានបន្ទប់សំរាកព្យាបាលជម្ងឺចំនួន២បន្ទប់ បំពាក់ដោយគ្រែចំនួន ១១ ពូកដេក១១ ខ្នើយកើយ១១, បន្ទប់សំរាប់បុគ្គលិកពេទ្យសំរាក ១បន្ទប់, បន្ទប់សំរាប់ដាក់សម្ភារៈពេទ្យ ១បន្ទប់ ប៉ុន្តែនៅមិនទាន់មានបុគ្គលិកពេទ្យ សម្ភារៈ និងថ្នាំសំរាប់ព្យាបាល ។

អាជ្ញាធរជាតិ ក៏បានពិភាក្សារួមគ្នាជាមួយក្រុមប្រតិភូបច្ចេកទេសរបស់វៀតណាម ដែលបានមកកម្ពុជាដើម្បីពិនិត្យជាក់ស្តែងពីទីតាំងនិងទំហំដីដែលត្រូវសាងសង់មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនលើបញ្ហាចំនួន ៦ ចំណុចដែលកម្ពុជាបានដាក់ចេញជារបៀបវារៈ គឺ ទី១. អំពី ទីតាំងដីនិងទំហំដីសំរាប់សាងសង់មជ្ឈមណ្ឌល ទី២. អំពីច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ទី៣. អំពីរចនាសម្ព័ន្ធនិងយន្តការរបស់មជ្ឈមណ្ឌល ទី៤. អំពីកម្មវិធីដំណើរការរបស់មជ្ឈមណ្ឌល ទី៥. អំពី ប្រភពធនធាន( ធនធានមនុស្សនិងសម្ភារៈ) ទី៦. អំពីតម្រូវការសំណង់អាគារនិងសម្ភារៈ ដើម្បី ឈានទៅរកដំណោះស្រាយមួយបានសមស្រប ។

ក្រសួងសុខាភិបាល បានរៀបចំគោលការណ៍ណែនាំស្តីពីការបន្សាបគ្រឿងញៀនសំរាប់មណ្ឌលបណ្តោះអាសន្ន ដើម្បីរួមចំណែកក្នុងការពង្រឹងបច្ចេកទេសវេជ្ជសាស្ត្រសំរាប់ការបន្សាបគ្រឿងញៀន រួចរាល់ជាស្ថាពរ ដែលគោលការណ៍នេះអាចប្រើប្រាស់ជាមូលដ្ឋាន ដើម្បីបន្សាប ព្យាបាល ឬបញ្ជូនអ្នកញៀនគ្រឿងញៀនទៅកាន់សេវាសមស្រប និងបានធ្វើការអភិវឌ្ឍផែនការយុទ្ធសាស្ត្រ សេចក្តីណែនាំ និងសេវាព្យាបាលអ្នកញៀនគ្រឿងញៀន ។

**ចំពោះការកាត់បន្ថយគ្រោះថ្នាក់** អង្គការខាន់ណា បានសហការជាមួយអាជ្ញាធរជាតិ ដើម្បីរៀបចំប្រតិភូចម្រុះមួយក្រុមទៅធ្វើទស្សនកិច្ចសិក្សាស្វែងយល់អំពីការអនុវត្តន៍កម្មវិធីកាត់បន្ថយគ្រោះថ្នាក់ នៅប្រទេសម៉ាឡេស៊ី( ០៥-០៩/៧/២០១០ ។ នៅក្នុងដំណើរទស្សនកិច្ចនេះ ក្រុមប្រតិភូបានសិក្សាអំពីកម្មវិធីកាត់បន្ថយគ្រោះថ្នាក់នានាដែលបាននិងកំពុងអនុវត្តនៅប្រទេសម៉ាឡេស៊ី, បានសិក្សាអំពីជោគជ័យរបស់ប្រទេសម៉ាឡេស៊ីក្នុងការកាត់បន្ថយមេរោគអេដស៍ដែលពាក់ព័ន្ធនឹងកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។ ជាមួយនេះ ក្រុមប្រតិភូក៏បានទៅទស្សនកិច្ចផ្ទាល់អំពីកម្មវិធីមេតាដូនរបស់ស្ថាប័នត្រួតពិនិត្យគ្រឿងញៀន, កម្មវិធីមេតាដូននៅក្នុងពន្ធនាគារ, កម្មវិធីមេតាដូន និង កម្មវិធីម្ជុល/ស៊ីរាំង របស់គ្លីនិកឯកជន និងអង្គការមិនមែនរដ្ឋាភិបាល, កម្មវិធីមេតាដូន របស់មន្ទីរពេទ្យសាធារណៈ និងការអនុវត្តន៍កម្មវិធីម្ជុល/ស៊ីរាំង ក្នុងសហគមន៍របស់អង្គការមិនមែនរដ្ឋាភិបាល ។

## ៤. ការពង្រឹងសមត្ថភាពអនុវត្តច្បាប់

អាជ្ញាធរជាតិបានបន្តកិច្ចសហការ ជាមួយអគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ ក្នុងការអនុវត្តន៍គម្រោងផែនការសកម្មភាពសំរាប់ឆ្នាំ២០១០ ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា ដែលគម្រោងនេះនឹងត្រូវធ្វើការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់នៅតាមរាជធានី-ខេត្តចំនួន១០ (រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តព្រះវិហារ ខេត្តសៀមរាប ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង ខេត្តកណ្តាល) ចាប់ពីខែកក្កដារហូតដល់ខែវិច្ឆិកា ឆ្នាំ២០១០ ។

អាជ្ញាធរជាតិ បានជួបជាមួយតំណាងការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្មនៃអង្គការសហប្រជាជាតិ (UNODC) ប្រចាំនៅទីក្រុងភ្នំពេញ ដើម្បីពិភាក្សាអំពីការប្រគល់ និង ទទួលនូវសម្ភារៈការិយាល័យទំនាក់ទំនងព្រំដែន(BLO) មួយកន្លែងនៅភូមិកំពង់ស្រឡៅ ឃុំកំពង់ស្រឡៅ ស្រុកឆែប ខេត្តព្រះវិហារ ព្រមទាំងស្នើសុំឱ្យ UNODC បន្តជួយពង្រឹងសមត្ថភាពអនុវត្តច្បាប់ និងផ្តល់នូវមធ្យោបាយសំរាប់កិច្ចប្រតិបត្តិការ ។

តបតាមការស្នើសុំ របស់ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល អាជ្ញាធរជាតិបានចាត់តាំងមន្ត្រីជំនាញ១រូប ទៅចូលរួមសិក្ខាសាលាស្តីពីច្បាប់របស់សហគមន៍អឺរ៉ុប(០១-០២/៧/២០១០) នៅសណ្ឋាគារភ្នំពេញ ដែលសិក្ខាសាលានេះគាំទ្រដោយ UNODC ក្នុងគោលបំណងផ្សព្វផ្សាយដល់មន្ត្រី នៃក្រសួង-ស្ថាប័នទទួលបន្ទុកគ្រប់គ្រងសារធាតុគីមីផ្សំ នាំចូល និង ប្រើប្រាស់ក្នុងប្រទេស ។

ជាមួយបណ្តាប្រទេសក្នុងតំបន់ យើងបានបញ្ជូនមន្ត្រីទៅចូលរួមក្នុងសិក្ខាសាលាស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន (២៨-២៩.៦.២០១០) នៅប្រទេសឥណ្ឌូនេស៊ី ដែលសិក្ខាសាលានេះ គឺជាសិក្ខាសាលារួមគ្នារវាងការិយាល័យអគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ ជាមួយក្រុមប្រឹក្សាជាតិប្រឆាំងគ្រឿងញៀនឥណ្ឌូនេស៊ី ក្នុងក្របខណ្ឌអាស៊ាន + កូរ៉េ ដើម្បីពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅក្នុងតំបន់ ដោយផ្តោតសំខាន់លើសកម្មភាពចំនួន ៤ គឺ :

១. ការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ និង មន្ត្រីមន្ទីរពិសោធន៍ ទាំងនៅក្នុងប្រទេស និងនៅសាធារណរដ្ឋកូរ៉េ ។

២. ការផ្តល់សម្ភារៈសំរាប់អង្គភាពអនុវត្តច្បាប់នៅទូទាំងប្រទេស ។

៣. ការផ្តល់ឧបករណ៍មន្ទីរពិសោធន៍គ្រឿងញៀនចំនួន១សម្រាប់ ដល់អគ្គលេខាធិការដ្ឋាន អជបគញ ។

៤. ការផ្តល់សម្ភារៈ និង មធ្យោបាយ សំរាប់សកម្មភាពឃោសនាផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន ។

សំរាប់ប្រទេសកម្ពុជា រដ្ឋាភិបាលកូរ៉េ តាមរយៈការិយាល័យអគ្គរដ្ឋអាជ្ញា បានសម្រេចផ្តល់គំរោងមួយសំរាប់ឆ្នាំ ២០១០ ដែលមានឈ្មោះថា "ការធ្វើឱ្យប្រសើរឡើងថែមទៀត សំរាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀននិងការរីករាលដាលនៃគ្រឿងញៀន ។ ដោយឡែក ដើម្បីបង្កលក្ខណៈដល់ការិយាល័យអគ្គរដ្ឋអាជ្ញាកូរ៉េ ក្នុងការជួយឧបត្ថម្ភគាំទ្រដល់បណ្តាប្រទេសអាស៊ាន ភាគីកូរ៉េបានស្នើសុំឱ្យមានការចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នាស្តីពី "មជ្ឈមណ្ឌលសម្របសម្រួលព័ត៌មានប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក" ។

### ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ ៖

យោងតាមអនុស្សារណៈនៃការយោគយល់គ្នាទ្វេភាគី កម្ពុជា-រុស្សី ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ស្ថានឯកអគ្គរដ្ឋទូតរុស្សីប្រចាំនៅកម្ពុជា បានជំរាបពីកាលបរិច្ឆេទនៃការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់ គឺនៅឆមាសទី១ ឆ្នាំ២០១១ និងបញ្ជូនមន្ត្រីអនុវត្តច្បាប់កម្ពុជា ធ្វើការងារសាកល្បងនៅមជ្ឈមណ្ឌលជំនាញនៃ ប្រទេសរុស្សី នាឆមាសទី២ ឆ្នាំ២០១១ ។

នៅថ្ងៃទី២៩ខែកក្កដាឆ្នាំ២០១០ អាជ្ញាធរជាតិបានទទួលក្រុមប្រតិភូបច្ចេកទេសរបស់វៀតណាម ដែលបានអញ្ជើញមកកម្ពុជា ដើម្បីពិភាក្សាពីដំណើរការសាងសង់មជ្ឈមណ្ឌលជាតិព្យាបាល និង ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

បានបញ្ជូនមន្ត្រីអនុវត្តច្បាប់ ទៅចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលនៅសាធារណរដ្ឋកូរ៉េ ពីខែកក្កដាដល់ខែសីហា ឆ្នាំ២០១០ ។

## III . ការសន្និដ្ឋាន និង វាយតម្លៃ ៖

ជារួម នៅក្នុងខែកក្កដានេះអាជ្ញាធរជាតិបានបន្តយកចិត្តទុកដាក់ដឹកនាំក្រសួងជាសមាជិក និងបំផុសលើកទឹកចិត្តឱ្យមានការចូលរួមពីបណ្តាអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ អង្គការសង្គមស៊ីវិល និង វិស័យឯកជន អនុវត្តនូវផែនការសកម្មភាពពហុវិស័យ ដើម្បីទប់ស្កាត់បញ្ហាគ្រឿងញៀនទទួលបានលទ្ធផលគួរកត់សំគាល់ ក្នុងនោះ ៖

**លើការកាត់បន្ថយតម្រូវការគ្រឿងញៀន** អាជ្ញាធរជាតិ ក្រសួង-ស្ថាប័ន ក៏ដូចជាគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានយកចិត្តទុកដាក់សំខាន់លើការផ្សព្វផ្សាយអប់រំដើម្បីលើកកំពស់ការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន ជាពិសេស តាមរយៈការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦មិថុនា២០១០ មកដល់ខែកក្កដានេះ ក៏នៅមានខេត្តមួយចំនួនបានបន្តរៀបចំទិវានេះ (សរុបមាន២៣រាជធានី-ខេត្ត) ។ ការប្រារព្ធទិវាខាងលើ នៅក្នុងឆ្នាំនេះបានប្រព្រឹត្តទៅយ៉ាងផុលផុសដោយមានការចូលរួមពីសំណាក់ មន្ត្រីរាជការ លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស ម្ចាស់មូលដ្ឋានអាជីវកម្មនានា និងប្រជាពលរដ្ឋនៅក្នុងរាជធានី-ខេត្ត ញ៉ាំងឱ្យការផ្សព្វផ្សាយអប់រំបានស៊ីជម្រៅដល់មូលដ្ឋានសហគមន៍ និងបានចំមុខសញ្ញាងាយទទួលរងគ្រោះថ្នាក់ ។ ប៉ុន្តែយើងក៏ត្រូវរិះរកវិធីសាស្ត្រដ៏មានប្រសិទ្ធភាពថ្មីៗបន្ថែមទៀត សំរាប់ការអប់រំចំពោះមុខសញ្ញាងាយទទួលរងគ្រោះផ្សេងទៀត ដូចជា ក្រុមសិស្សដែលមិនចូលសាលារៀន ក្រុមយុវជនក្រៅប្រព័ន្ធអប់រំ និងអ្នកប៉ះពាល់គ្រឿងញៀន ជាដើម ដែលពួកគេមិនសូវបានទទួលការអប់រំអំពីគ្រោះថ្នាក់នៃគ្រឿងញៀននេះ ។

**លើការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន** តាមរបាយការណ៍បានបង្ហាញថាបទល្មើសគ្រឿងញៀនមានការថយចុះ តែក្រុមឈ្មួញបានធ្វើសកម្មភាពជួញដូរចែកចាយគ្រឿងញៀនតាមរូបភាពតូចៗជាច្រើនកន្លែង ។ យើងបានធ្វើការសន្និដ្ឋានថា គឺមិនមែនបទល្មើសគ្រឿងញៀននោះទេ ធាតុពិត មន្ត្រីអនុវត្តច្បាប់នៅមូលដ្ឋានហាក់ដូចជាមានភាពរយាលចំពោះសកម្មភាពបង្ក្រាបបទល្មើស ឯការបង្ក្រាបបទល្មើសទៀតសោតក៏មិនបានព្រមៗគ្នាគ្រប់ទីកន្លែង ។ ជាក់ស្តែង នៅក្នុងខែកក្កដានេះ យើងទទួលបានរបាយការណ៍ស្តីពីលទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀនពីរាជធានី-ខេត្តតែ ៨ ប៉ុណ្ណោះ លើ២៤ រាជធានី-ខេត្ត ។ ដូច្នេះការងារនេះទាមទារឱ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្តនីមួយៗ ត្រូវយកចិត្ត

ទុកដាក់ជំរុញដល់អាជ្ញាធរនៅមូលដ្ឋានឱ្យបានសកម្មថែមទៀតលើការងារបង្ក្រាបបទល្មើស ដើម្បីចូលរួមចំណែកក្នុងការថែរក្សាសន្តិសុខនិងសណ្តាប់សង្គមជាតិ ។

**លើការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន** យើងបានខិតខំប្រឹងប្រែងធ្វើឱ្យមានការរីកចំរើនជាបន្តបន្ទាប់ ជាអាទិ៍ ការរៀបចំគោលការណ៍ណែនាំ ស្តីពីការបន្សាបគ្រឿងញៀនសំរាប់មណ្ឌលបណ្តោះអាសន្ន ដើម្បីរួមចំណែកក្នុងការពង្រឹងបច្ចេកទេសវេជ្ជសាស្ត្រសំរាប់ការបន្សាបគ្រឿងញៀន ព្រមជាមួយគ្នានឹងការដាក់បញ្ចូលទៅក្នុងជំពូកចំណាយដោយថវិកាជាតិសំរាប់ទិញថ្នាំព្យាបាលអ្នកញៀនគ្រឿងញៀន ។ ប៉ុន្តែយើងនៅមានកិច្ចការចំពោះមុខជាច្រើនទៀតដែលត្រូវធ្វើ ដូចជា ការរៀបចំគោលនយោបាយ និងបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធនឹងមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន, ការរៀបចំរចនាសម្ព័ន្ធនិងយន្តការរបស់មជ្ឈមណ្ឌលជាតិ, ការរៀបចំកម្មវិធីសំរាប់ដំណើរការនៅក្នុងមជ្ឈមណ្ឌល, ការស្វែងរកប្រភពធនធានមនុស្សនិងសម្ភារៈ សំរាប់មជ្ឈមណ្ឌលជាតិ និងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសំរាប់អប់រំ បន្សាប ព្យាបាលគ្រឿងញៀន ដែលមានបច្ចុប្បន្ន ។

## IV. ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែសីហា ឆ្នាំ២០១០ :

ដូចបានធ្វើការសន្និដ្ឋាននិងវាយតម្លៃអំពីសភាពការណ៍គ្រឿងញៀន និងចំណុចប្រឈមក្នុងការអនុវត្តន៍យុទ្ធសាស្ត្រខាងលើ អាជ្ញាធរជាតិបានដាក់ចេញនូវទិសដៅដើម្បីអនុវត្តបន្តដូចតទៅ :

### ***១.ការងារកាត់បន្ថយតម្រូវការគ្រឿងញៀន :***

-បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំបង្កើតផ្ទាំងរូបភាព ខិត្តប័ណ្ណដែលមានខ្លឹមសាររួមបញ្ចូលគ្នាសំរាប់ធ្វើការផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀននៅតាមសណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត ។

-បន្តកិច្ចសហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីក្រសួងជួយអន្តរាគមន៍ទៅក្រុមហ៊ុនទូរស័ព្ទចល័ត ក្នុងការបញ្ចូលសារអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀនទៅកាន់អតិថិជនរបស់ខ្លួន ។

-បន្តកិច្ចសហការជាមួយក្រសួងជាសមាជិក ក្នុងការជំរុញការផ្សព្វផ្សាយអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ រួមមានវិទ្យុ- ទូរទស្សន៍( រដ្ឋ-ឯកជន) រួមទាំងការងារផ្តល់បទសម្ភាសន៍ផ្សេងៗដែលពាក់ព័ន្ធបញ្ហាគ្រឿងញៀន ។

-បំផុសលើកទឹកចិត្តឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងវិស័យឯកជន ក្នុងការចូលរួមផ្សព្វផ្សាយលើកកំពស់ការយល់ដឹងពីគ្រឿងញៀន ។

### ***២.ការព្យាបាល ស្តារនីតិសម្បទា និង សមាហរណកម្ម និងការកាត់បន្ថយគ្រោះថ្នាក់នានា***

-បន្តកិច្ចដំណើរការសាងសង់មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

-បន្តការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងលិខិតបទដ្ឋានស្តីពីតំរូវការអប្បបរមាក្នុងការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

-បន្តជំរុញការតម្លើងបញ្ជីឈ្មោះ ឃុំ-សង្កាត់អាទិភាព សំរាប់ធ្វើសកម្មភាពត្រួតពិនិត្យគ្រឿងញៀននៅឆ្នាំ២០១០, ឈ្មោះនិងទីតាំងមណ្ឌលសុខភាព, ឈ្មោះទីតាំង និង វិសាលភាព នៃការអនុវត្តន៏ការងាររបស់អង្គការមិនមែន

រដ្ឋាភិបាល ដែលធ្វើការងារពាក់ព័ន្ធនឹងគ្រឿងញៀន និងជម្ងឺអេដស៍នៅរាជធានី-ខេត្ត ។

-ស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ និងសប្បុរសជន ដើម្បីជួយគាំទ្រផ្នែកសម្ភារៈបច្ចេកទេស សំរាប់បំពាក់ឱ្យមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសំរាប់ទទួលអប់រំ បន្សាប ព្យាបាលគ្រឿងញៀន ដែលមានស្រាប់ ។

-ត្រៀមលក្ខណៈជូន ឯកឧត្តមអគ្គលេខាធិការ ចូលរួមជាអធិបតីនៅក្នុងកិច្ចប្រជុំក្រុមការងារអេដស៍-គ្រឿងញៀន នាថ្ងៃទី០៣ខែសីហាឆ្នាំ២០១០ នៅសណ្ឋាគារសានវេ ។

### ៣-ការពង្រឹងសមត្ថភាពអនុវត្តច្បាប់

-បន្តកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-កូរ៉េ ដោយមានការចូលរួមគាំទ្រពីអង្គការ Khana USAID USAID រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់គ្រឿងញៀន នៅរាជធានីភ្នំពេញ និង ខេត្តចំនួន៩ (ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តព្រះវិហារ ខេត្តសៀមរាប ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង និង ខេត្តកណ្តាល) ចាប់ពី ខែកក្កដា រហូតដល់ ខែវិច្ឆិកា ។

-ត្រៀមបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅខេត្តកំពង់ស្ពឺ រួមបញ្ចូលគ្នាជាមួយកម្មវិធីកាត់បន្ថយគ្រោះថ្នាក់នានា ដែលគាំទ្រថវិកាដោយអង្គការ Khana ។

-សម្របសម្រួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ដើម្បីជំរុញឱ្យអាជ្ញាធរមូលដ្ឋានយកចិត្តទុកដាក់ធ្វើកិច្ចសន្យារដ្ឋបាលឱ្យបានហ្មឺងម៉ាត់ ជាមួយម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត និង កន្លែងសប្បាយនានា នៅមូលដ្ឋានរបស់ខ្លួន ។

-ជំរុញនិងជួយគាំទ្រផ្នែកបច្ចេកទេស ដល់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងការរៀបចំផែនការសកម្មភាពត្រួតពិនិត្យសារធាតុគីមីផ្សំ ឆ្នាំ២០១១ ។

### ៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ

-ត្រៀមលក្ខណៈជូនគណៈប្រតិភូនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណៈរដ្ឋសង្គមនិយមវៀតណាម ពីថ្ងៃទី០៩ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១០ ។

-ត្រៀមទៅចូលរួមសិក្ខាសាលាស្តីពីកម្មវិធី Global Smart ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក នៅទីក្រុងបាងកក ប្រទេសថៃ (ថ្ងៃទី០៥-០៦/៨/២០១០) ។

-ត្រៀមទៅចូលរួមក្នុងកិច្ចប្រជុំទ្វេភាគី កម្ពុជា-ថៃ លើកទី៥ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន នៅខេត្តត្រាត ប្រទេសថៃ ។

ទន្ទឹមនេះ ដើម្បីអនុវត្តបានសំរេចផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀនខាងលើ អាជ្ញាធរជាតិនឹងបន្តជំរុញការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ក្នុងនោះសំខាន់គឺ :

-បន្តជំរុញការធ្វើបច្ចុប្បន្នភាពទិន្នន័យព័ត៌មានគ្រឿងញៀន តាមគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ។

-បន្តអនុវត្តន៍ផែនការប្រតិបត្តិគំរូនៅខេត្តបន្ទាយមានជ័យ ក្នុងនោះ យកចិត្តទុកដាក់ប្រជុំដកពិសោធន៍លើការងាររបស់អនុគណៈកម្មការផ្សព្វផ្សាយអប់រំ, អនុគណៈកម្មការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និង អនុគណៈកម្មការបូកសរុបនិងវាយតម្លៃ ។

-ការបន្តរៀបចំសាលារៀនពណ៌បៃតងគំរូនៅវិទ្យាល័យឥន្ទ្រទេវី ដើម្បីអនុវត្តគោលការណ៍ ៥ យ៉ាង "**ពីរមិន បីត្រូវ**" និង អនុវត្តវិធានការ ១៥ យ៉ាង ។

-ការបង្កើតយន្តការសំរាប់អនុវត្តនិងតាមដានវាយតម្លៃលើការអនុវត្តន៍ គោលការណ៍ទាំង៥ និង វិធានការទាំង ១៥ សំរាប់សាលារៀនពណ៌បៃតងគំរូ ។

-ការពង្រឹងរចនាសម្ព័ន្ធអាជ្ញាធរជាតិ និង សមត្ថភាពរបស់អគ្គលេខាធិការដ្ឋាន ។

-ការជំរុញការរៀបចំផែនការសកម្មភាពជាតិ៥ឆ្នាំលើកទី២(២០១១-២០១៥)ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អគ្គលេខាធិការ**

**<u>ចំលងជូន</u> :**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អជបគញ

(ដើម្បីជូនជ្រាប)

-ក្រសួងសមាជិក អ.ជ.ប.គ.ញ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត

-នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

(ដើម្បីមុខការ)

-ឯកសារ-កាលប្បវត្តិ

# ឈ្មោះខេត្តដែលបានប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

| អង្គភាព | ខ្លឹមសារ | សមាសភាព | ចំនួន |
|---|---|---|---|
| ន.ប កំពង់ធំ សហការជាមួយ អង្គការ CODCC | គ្រោះថ្នាក់នៃគ្រឿងញៀន | សហគមន៍មូលដ្ឋាន ស្រុកបារាយ ប្រាសាទសំបូរ សន្ទុក | ១៤៦ នាក់ |
| ន.ប កំពង់ធំ | គ្រោះថ្នាក់នៃគ្រឿងញៀន | មេក្រុម១០ខ្នង បានចំនួន ៣៨០ ខ្នងផ្ទះ (ស្មើនឹងប្រហែល) | ៤៨២ នាក់ |
| ន.ប កំពង់ធំ | បំរាមមិនឱ្យប្រើ គ្រ.ញ | ផ្ទះសំណាក់ សណ្ឋាគារ ខារាអូខេ និង ទីកម្សាន្ត ចំនួន ៥ កន្លែង | |
| ន.ប កណ្តាល | គ្រោះថ្នាក់នៃគ្រឿងញៀន | មុខសញ្ញាងាយរងគ្រោះ នៅឃុំកោះចិន ឃុំកំពង់អុស ឃុំព្រែកព្នៅ | ២៨៥ នាក់ |
| ន.ប ព្រៃវែង | គ្រោះថ្នាក់នៃគ្រឿងញៀន | បុគ្គលិក សាស្ត្រាចារ្យ និស្សិត | ១១០ នាក់ |
| ន.ប ពោធិសាត់ | ចុះធ្វើកិច្ចសន្យារដ្ឋបាល | កន្លែងម៉ាស្សា ១ កន្លែង | |
| ន.ប ស្វាយរៀង | គ្រោះថ្នាក់នៃគ្រឿងញៀន | ក្រុមប្រឹក្សាឃុំ មេភូមិ ប្រជាពលរដ្ឋ | ៤២ នាក់ |
| សមាគមយុវជនខេត្តកណ្តាល | គ្រោះថ្នាក់នៃគ្រឿងញៀន | ប្រគំតន្ត្រី មានសំណួរ-ចម្លើយ ពាក់ព័ន្ធនឹងគ្រឿងញៀន | |
| សមាគមអភិវឌ្ឍន៍សេដ្ឋកិច្ច ខេត្តស្ទឹងត្រែង | គ្រោះថ្នាក់នៃគ្រឿងញៀន | ក្រុមប្រឹក្សាឃុំ មេភូមិ | ២៦ នាក់ |
| បណ្តាញសមាគមយុវជនខ្មែរ នៅប៉ៃលិន | គ្រោះថ្នាក់នៃគ្រឿងញៀន | ស្ត្រីបំរើសេវាកម្សាន្ត | ៩៧ នាក់ |
| **ការរៀបចំមីទ្ទិញអបអរសាទរ ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា ២០១០** | | | |
| ខេត្តកំពង់ស្ពឺ | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ១៩៣៧ នាក់ |
| រាជធានីភ្នំពេញ | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ១.០០០ នាក់ |
| ខេត្តកណ្តាល | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ៦៥២ នាក់ |
| ខេត្តកែប | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ៣៥០ នាក់ |
| ខេត្តកោះកុង | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ៤២៥ នាក់ |
| ខេត្តមណ្ឌលគីរី | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ១.០៧០ នាក់ |
| ខេត្តរតនគីរី | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ៦៦៣ នាក់ |
| ខេត្តស្ទឹងត្រែង | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ៦១០ នាក់ |
| ខេត្តសៀមរាប | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ៣.០០០ នាក់ |
| ខេត្តបាត់ដំបង | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ២.៩៧៧ នាក់ |
| ខេត្តប៉ៃលិន | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ១.៧៧០ នាក់ |
| ខេត្តកំពង់ចាម | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ៥៩៥ នាក់ |
| ខេត្តកំពង់ឆ្នាំង | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ៤១០ នាក់ |
| ខេត្តកំពង់ធំ | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ៦៤៧ នាក់ |
| សាលាខេត្តកំពង់ធំ | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ៦៣០ នាក់ |
| សាលាខេត្តកំពត | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ៦.២១៣ នាក់ |
| ខេត្តក្រចេះ | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ១.៣៥២ នាក់ |
| ខេត្តឧត្តរមានជ័យ | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ៤.៨២៣ នាក់ |
| ខេត្តព្រះសីហនុ | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ១.២០០ នាក់ |
| ខេត្តពោធិសាត់ | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ៦០៨ នាក់ |
| ខេត្តស្វាយរៀង | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ១.២០២ នាក់ |
| ខេត្តតាកែវ | រៀបចំជាមីទ្ទិញ | ពលរដ្ឋ មន្ត្រីរាជការ គ្រូ សិស្ស អាជីវករ ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ | ៤៧០ នាក់ |
| **សរុប** | | | **៣៤.៩៧៤ នាក់** |

## អង្គភាពប្រតិបត្តិការបង្ក្រាបបទល្មើស រួមមាន :

| ល.រ | អង្គភាពបង្ក្រាប | សរុបរួម | | | ចរាចរជួញដូរចែកចាយ | | | ប្រើប្រាស់គ្រឿងញៀន | | | ចាប់តាមដីកា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី |
| ១ | មន្ទីរប្រឆាំងគ្រឿងញៀន | **៦** | **១១** | **២** | ៦ | ១១ | ២ | | | | | | |
| ២ | ន.ប ភ្នំពេញ | **៤** | **៩** | **០** | ៣ | ៦ | ០ | ១ | ៣ | ០ | | | |
| ៣ | ន.ប កំពង់ចាម | **៣** | **៤** | **២** | ៣ | ៤ | ២ | | | | | | |
| ៤ | ន.ប ព្រះសីហនុ | **១** | **២** | **១** | ១ | ២ | ១ | | | | | | |
| ៥ | ន.ប ព្រៃវែង | **១** | **២** | **១** | ១ | ២ | ១ | | | | | | |
| ៦ | ន.ប ព្រះវិហារ | **១** | **២** | **០** | ១ | ២ | ០ | | | | | | |
| ៧ | ន.ប បាត់ដំបង | **៥** | **៦** | **៣** | ៤ | ៥ | ៣ | ១ | ១ | ០ | | | |
| ៨ | ន.ប កំពត | **១** | **៥** | **០** | | | | ១ | ៥ | ០ | | | |
| ៩ | ន.ប បន្ទាយមានជ័យ | **៣** | **១០** | **៣** | ៣ | ៩ | ៣ | | | | ០ | ១ | ០ |
| ១០ | ន.ប ក្រចេះ | **១** | **៤** | **១** | ១ | ៤ | ១ | | | | | | |
| **សរុប** | | **២៦** | **៥៥** | **១៣** | **២៣** | ៤៥ | ១៣ | **៣** | ៩ | ០ | **០** | ១ | ០ |

## ទិន្នន័យសារធាតុគីមីផ្សំ

| ឈ្មោះ សារធាតុគីមីផ្សំ | ក្រសួងសុខាភិបាល | | ក្រសួងឧស្សាហកម្ម | | ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា | | សរុប | |
|---|---|---|---|---|---|---|---|---|
| | Kg | L | Kg | L | Kg | L | Kg | L |
| Acid Acetic | | | | | 125.600 | | **125.600** | |
| NAOH | | | | | 123.600 | | **123.600** | |
| Soda Ash | | | 40.000 | | 550.400 | | **590.400** | |
| Sodium Sulfate | | | | | 580.000 | | **580.000** | |
| Methylene Chloride | | | | | 37.500 | | **37.500** | |
| Toluene | | | 45.000 | | 39.100 | | **84.100** | |
| Acetone | | | 6.000 | | | | **6.000** | |
| Ethyl Acetate | | | 5.000 | | | | **5.000** | |
| Xylene | | | 134.500 | | | | **134.500** | |
| Thinner | | | 135.000 | | | | **135.000** | |
| HCL | | | 120.000 | | | | **120.000** | |
| Caustic Soda | | | 48.000 | | | | **48.000** | |
| Methyl Ethyl Ketone | | | 500 | | | | **500** | |
| ***Total :*** | | | **534.000** | | **1.456.200** | | **1.990.200** | |